ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៨៤/២០២៥ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

# កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី លើកទី៣ រវាងកម្ពុជានិងជប៉ុន

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ ឯកឧត្តម អ៊ឹង រចនា រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម NAMAZU Hiroyuki អនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន បានធ្វើជាសហប្រធាននៃកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីលើកទី៣ រវាងក្រសួងការបរទេសទាំងពីរ។

ក្នុងអំឡុងពេលស្នាក់នៅកម្ពុជា ឯកឧត្តម NAMAZU Hiroyuki បានចូលជួបសម្ដែងការគួរសមចំពោះ**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយបានផ្លាស់ប្ដូរយោបល់គ្នាលើកិច្ចសហប្រតិបត្តិការតំបន់ និងពហុភាគី រួមទាំងជម្លោះព្រំដែនកម្ពុជា-ថៃ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់អំពីជំហរប្រកបដោយសង្គតិភាពរបស់កម្ពុជា និងមាគ៌ាឆ្ពោះទៅរកដំណោះស្រាយដោយសន្តិវិធីសម្រាប់ជម្លោះព្រំដែន ដែលកាន់តែមានភាពតានតឹង ចាប់តាំងពីផ្ទុះការប្រយុទ្ធគ្នាសាជាថ្មី នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥។

កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីនេះ បានកត់សម្គាល់ដោយការពេញចិត្តយ៉ាងខ្លាំងចំពោះវឌ្ឍនភាពសំខាន់ៗក្នុងវិស័យគន្លឹះនៃកិច្ចសហប្រតិបត្តិការទ្វេភាគីដែលសម្រេចបាន ចាប់តាំងពីកិច្ចប្រជុំឧត្តមមន្ត្រីលើកទីពីរ។ ភាគីទាំងពីរបានឯកភាពគ្នាថា ការផ្លាស់ប្ដូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងជាញឹកញាប់ នៅគ្រប់កម្រិត និងគ្រប់ដណ្ដប់លើវិស័យជាច្រើន ជាពិសេសទស្សនកិច្ចរបស់**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅជប៉ុន ក្នុងខែឧសភា បានរួមចំណែកដ៏ធំធេងដល់ការធ្វើឱ្យកាន់តែស៊ីជម្រៅនូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងជប៉ុន។

កិច្ចប្រជុំបានសម្ដែងនូវការកោតសរសើរយ៉ាងខ្លាំងចំពោះការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអភិក្រមថ្មីនៃកិច្ចសហប្រតិបត្តិការ និងបានឯកភាពគ្នាលើកកម្ពស់យ៉ាងសកម្មនូវកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តកញ្ចប់សហបង្កើតសេដ្ឋកិច្ច ដែលត្រូវបានដាក់ចេញកាលពីខែឧសភាកន្លងទៅ ក្នុងគោលបំណងពង្រីកទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី និងទាក់ទាញការវិនិយោគរបស់ជប៉ុនមកកាន់កម្ពុជាបន្ថែមទៀត។

ចំពោះជម្លោះព្រំដែនកម្ពុជា-ថៃដែលកំពុងមានភាពតានតឹងកាន់តែខ្លាំង ភាគីទាំងពីរបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃដំណោះស្រាយដោយសន្តិវិធីតាមរយៈការសន្ទនា ការបញ្ឈប់អរិភាព និងការវិលត្រឡប់របស់ជនភៀសសឹកទៅកាន់លំនៅឋានរបស់ពួកគេវិញដោយសុវត្ថិភាព។ កិច្ចប្រជុំក៏បានពិភាក្សាអំពីការវិវត្តថ្មីៗក្នុងតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ទៅវិញទៅមក។

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥